00946470

E295/5/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 30 / 08 / 2013
ម៉ោង (Time/Heure): 11:08
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៣

**ជូនចំពោះ:** ភាគីនៃសំណុំរឿង ០០២

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់ នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំបញ្ជីឯកសារទាំងអស់ដែលត្រូវបានទទួលយកជា ភស្តុតាងក្នុងសំណុំរឿង ០០២/០១ (ឯកសារ E295/5)។

1. នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ បន្ទាប់ពីបានឃើញសំណើសុំបញ្ជីនៃឯកសារទាំងអស់ដែលត្រូវបានទទួលយកជាភស្តុតាងក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានណែនាំដល់ភាគីនានាឱ្យយោងទៅលើចំណាត់ថ្នាក់ឯកសារ E3 ដែលត្រូវបានបង្ហាញនៅក្នុងឧបសម្ព័ន្ធទាំងឡាយនៃសេចក្តីសម្រេចស្តាពរលើឯកសារ (ឯកសារ E299 និង E185/2) រហូតដល់ពេលដែលប្រព័ន្ធ Zylab ត្រូវបានធ្វើបច្ចុប្បន្នភាពរួចហើយ (ឯកសារ E295/4 កថាខណ្ឌ ៣)[1]។

[1] អនុស្សរណៈដែលមានចំណងជើងថា “កាលវិភាគដែលត្រូវបានកែប្រែសម្រាប់ការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល (ឯកសារ E295/1, E295/1/2, E295/1/3, E295/2 និង E295/3)” ត្រូវបានជូនដំណឹងដល់ភាគីនានា ជាឯកសារថតចម្លងជាការគួរសម កាលពីថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ និងត្រូវបានដាក់ជាផ្លូវការ កាលពីថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៣ (ឯកសារ E295/4)។

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ: (៨៥៥) -២៣-២១៨-៩១៤ ទូរសារ: (៨៥៥) -២៣-២១៨-៩៤១ គេហទំព័រ: www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh. Tel: +855(0)23218914 Fax:+ 855(0)23218941 Web: www.eccc.gov.kh

អង្គជំនុំជម្រះទទួលស្គាល់ថា ទោះបីជា ខៀវ សំផន (មិនមែន នួន ជា) ដូចដែលបានបង្ហាញនៅក្នុងឯកសារ E295/4 ដែលពីដើមឡើយជាអ្នកស្នើសុំបញ្ជីឯកសារទាំងអស់ដែលត្រូវបានទទួលយកជាភស្តុតាងក្នុងសំណុំរឿង ០០២/០១ (ឯកសារ E295/5 កថាខណ្ឌ ២) ក៏ដោយ ក៏ពេលនេះ អង្គជំនុំជម្រះបានទទួលនូវសំណើសុំមួយទៀតពី នួន ជា ទាក់ទងនឹងបញ្ជីដែលមានការរៀបចំ និងតាមលំដាប់លំដោយនៃរាល់ឯកសារទាំងអស់ដែលទទួលយកជាភស្តុតាង។ ដោយកត់សម្គាល់ឃើញថា ភស្តុតាងដែលបានទទួលយកត្រូវបានចុះបញ្ជីនៅក្នុងឧបសម្ព័ន្ធមួយចំនួនជាលំដាប់លំដោយ និងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីនៅក្នុងទម្រង់ជា PDF នោះ នួន ជា លើកឡើងថា បញ្ជីរួមមួយនឹងផ្តល់នូវភាពច្បាស់លាស់ពាក់ព័ន្ធនឹងឯកសារដែលត្រូវបានទទួលយកនៅពេលសវនាការ ហើយនឹងជួយដល់ជនជាប់ចោទនៅក្នុងការផ្តល់យោបល់ដល់មេធាវី ព្រមទាំងសម្រួល និងពន្លឿនការធ្វើសេចក្តីព្រាងសារណាបញ្ចប់ការពិភាក្សាដេញដោលផងដែរ (ឯកសារ E295/5)។

2. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា នៅក្នុងកិច្ចដំណើរការនីតិវិធីទាំងមូល មេធាវីការពារក្តីទាំងពីរក្រុម មានធនធានជាច្រើន រួមទាំងមន្ត្រីគ្រប់គ្រងសំណុំរឿងធ្វើការពេញម៉ោង ដើម្បីពិនិត្យតាមដានឯកសារសម្ភារៈដែលត្រូវបានបង្ហាញ និងទទួលយក។ នៅក្នុងកិច្ចដំណើរការនីតិវិធីទាំងមូល ភាគីនានាក៏ត្រូវបានផ្តល់នូវបញ្ជីច្បាស់លាស់ និងមានអត្ថន័យជាក់ច្បាស់នៃភស្តុតាងដែលត្រូវបានទទួលយកនៅក្នុងឧបសម្ព័ន្ធនានានៃសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរស្តីពីភាពអាចទទួលយកបាន ( ឯកសារ E185, E185/1, E185/2 និង E299) ផងដែរ និងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី នៅពេលមានកំណត់ហេតុនេះ។ លើសពីនេះទៀត បញ្ជីដែលត្រូវបានរៀបចំ និងតាមលំដាប់លំដោយនៃរាល់ឯកសារទាំងអស់ដែលត្រូវបានទទួលយកនៅក្នុងសំណុំរឿង ០០២/០១ មាននៅក្នុងប្រព័ន្ធ Zylab។ ភាគីនានាអាចទាញយកបញ្ជីនេះ ដើម្បីប្រើប្រាស់នៅក្នុងកម្មវិធីផ្សេងៗទៀតបានផងដែរ។

3. ដូចដែលអង្គជំនុំជម្រះបានទទួលស្គាល់កាលពីពេលមុនរួចហើយថា បច្ចុប្បន្ននេះ ប្រព័ន្ធ Zylab មិនអាចបង្ហាញពីលេខឯកសារ E3 ដែលត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃសេចក្តីសម្រេច

ស្តាពរស្តីពីឯកសារ (ឯកសារ E185/2 និង E299) និងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីឡើយ។ ហេតុដូច្នេះ នៅពេលប្រព័ន្ធ Zylab ត្រូវបានធ្វើបច្ចុប្បន្នភាពរួចហើយនោះ ភាគីអាចយោងលើបញ្ជីនៃភ័ស្តុតាងដែលបានបង្ហាញនៅក្នុងឧបសម្ព័ន្ធទាំងឡាយនៃសេចក្តីសម្រេចដែលពាក់ព័ន្ធ និងកំណត់ហេតុជាលាយលក្ខណ៍អក្សរស្តីពីកិច្ចដំណើរការនីតិវិធី ជាមួយនឹងបញ្ជីនៅក្នុងប្រព័ន្ធ Zylab (ឯកសារ E295/4 កថាខណ្ឌ ៣)។ ឧបសម្ព័ន្ធ និងកំណត់ហេតុជាលាយលក្ខណ៍អក្សរទាំងឡាយនៅក្នុងទម្រង់ PDF អាចត្រូវបានផ្លាស់ប្តូរទម្រង់បានដោយប្រើកម្មវិធីនានាដែលគ្រប់ភាគីទាំងអស់មាន។ ជាចុងក្រោយ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ភាគីអាចទទួលបានជំនួយបច្ចេកទេសពីផ្នែកគ្រប់គ្រងតុលាការ និងផ្នែកបច្ចេកវិជ្ជាព័ត៌មាន និងទំនាក់ទំនង។ ហេតុនេះ អង្គជំនុំជម្រះបដិសេធសំណើសុំឱ្យអង្គជំនុំជម្រះផ្តល់បញ្ជីនៃភ័ស្តុតាងទាំងអស់ដែលត្រូវបានទទួលយកនៅក្នុងសំណុំរឿង ០០២/០១។

4. នេះជាចម្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងឯកសារ E295/5។